ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

## ជំនួបរវាងឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
## និងឯកឧត្តម Yukio IMAGAWA អតីតឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា

******

នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០១៦ វេលាម៉ោង ១៧:០០ ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឱ្យ ឯកឧត្តម Yukio IMAGAWA អតីតឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា ហើយនិងជាតួអង្គមួយរូបនៃសន្និសីទទីក្រុងប៉ារីសលើកទី១ ស្តីពីសន្តិភាពនៅកម្ពុជា ចូលជួបសម្តែងការគួរសម នៅទីស្តីការក្រសួង ។

នៅក្នុងជំនួបនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** បានសម្តែងនូវការស្វាគមន៍ ដោយរីករាយ ចំពោះដំណើរទស្សនកិច្ចរបស់ឯកឧត្តម Yukio IMAGAWA មកកាន់កម្ពុជាជាថ្មីម្តងទៀត ដើម្បីចូលរួមក្នុងពិធីរំលឹកខួបលើកទី២៥ នៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានសំដែងការចាប់អារម្មណ៍ ចំពោះសុន្ទរកថា ដ៏មានអត្ថន័យរបស់ឯកឧត្តម Yukio IMAGAWA ដែលបានថ្លែងក្នុងឱកាសនៃការប្រារព្ធខួបនេះ ដែលបានរៀបចំធ្វើឡើងនៅទីស្តីការក្រសួងការបរទេស កាលពីពេលព្រឹកថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០១៦។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានរំលឹកឡើងវិញអំពីការខិតខំប្រឹងប្រែងរបស់ឯកឧត្តម IMAGAWA ក្នុងពេលដែលឯកឧត្តមបំពេញការងារជាឯកអគ្គរាជទូតទី១របស់ជប៉ុន ប្រចាំនៅកម្ពុជា ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ហើយបានថ្លែងអំណរគុណចំពោះការជួយឧបត្ថម្ភគ្រប់បែបយ៉ាង ហើយនិងការចូលរួមវិភាគទានដ៏សកម្មរបស់ជប៉ុន នៅក្នុងដំណើរការចរចាសន្តិភាពនៅកម្ពុជា ក៏ដូចជាក្នុងដំណើរការកសាង និងអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញ បន្ទាប់ពីការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្តែងនូវការវាយតម្លៃខ្ពស់ និងការពេញចិត្ត ចំពោះការរីកចម្រើនដ៏ល្អប្រសើរ ក្នុងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា-ជប៉ុន ហើយនិងជំនួយឧបត្ថម្ភលើគ្រប់វិស័យរបស់ជប៉ុនដល់កម្ពុជា ក្នុងការអភិវឌ្ឍប្រទេសជាតិរហូតដល់ពេលបច្ចុប្បន្ននេះ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្តែងនូវការរីករាយអំពីការចាប់ផ្តើមក្នុងពេលថ្មីៗ នូវជើងហោះហើរត្រង់រវាងជប៉ុន និងកម្ពុជា ហើយឯកឧត្តមបានសម្តែងនូវក្តីសង្ឃឹមថា ជើងហោះហើរត្រង់រវាងប្រទេសទាំងពីរនេះ នឹងជួយឱ្យមានការកើនឡើងនូវចំនួនទេសចរជប៉ុនមកទស្សនកិច្ចនៅកម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្ដែងនូវក្ដីសោមនស្សរីករាយ ចំពោះការកើនឡើងនៃទំនាក់ទំនងរវាងប្រទេសទាំងពីរលើផ្នែកទេសចរណ៍ និងលើផ្នែកវិនិយោគទុន ពិសេសគឺការកើនឡើងវិនិយោគទុនរបស់ជប៉ុនមកកម្ពុជាក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០១៦នេះ ដែល មានចំនួនប្រមាណ ២៥០លានដុល្លារអាមេរិក។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសម្ដែងនូវការស្វាគមន៍ផងដែរ ចំពោះការបង្កើតឡើង នូវមន្ទីរពេទ្យរបស់ជប៉ុន នៅកម្ពុជាក្នុងពេលថ្មីៗនេះ។

ឯកឧត្តម Yukio IMAGAWA បានសម្ដែងនូវអំណរគុណចំពោះ**ឯកឧត្តមទេសរដ្ឋមន្ត្រី** ដែលបានអញ្ជើញរូបឯកឧត្តមមកទស្សនកិច្ចនៅកម្ពុជា និងចូលរួមក្នុងការប្រារព្ធខួបលើកទី២៥ នៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ហើយឯកឧត្តមបានជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីការស្រលាញ់ពេញចិត្តរបស់ឯកឧត្តមចំពោះកម្ពុជា ក្នុងពេលដែលឯកឧត្តមស្នាក់នៅ និងបំពេញបេសកកម្មការទូតនៅកម្ពុជានាពេលនោះ ហើយឯកឧត្តមបានគូសបញ្ជាក់ថា ឯកឧត្តមបានចាត់ទុកកម្ពុជាគឺជាប្រទេសកំណើតទី២របស់ឯកឧត្តម។ ឯកឧត្តមបានសម្ដែងមនោសញ្ចេតនាសប្បាយរីករាយយ៉ាងខ្លាំង ដែលបានវិលត្រឡប់មកប្រទេសកំណើតទី២របស់ឯកឧត្តមនៅពេលនេះ។

ឯកឧត្តម Yukio IMAGAWA ក៏បានសម្ដែងនូវការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះការរីកចម្រើនប្រកបដោយផ្លែផ្កាក្នុងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងជប៉ុននិងកម្ពុជា។ ឯកឧត្តមបានគូសបញ្ជាក់ពីភាពងាយស្រួលខ្លាំង ក្នុងការធ្វើដំណើររបស់ឯកឧត្តមមកកាន់កម្ពុជាតាមជើងហោះហើរត្រង់ ដែលទើបបង្កើតឡើងថ្មីៗនេះ ហើយឯកឧត្តមបានបង្ហាញក្តីសង្ឃឹមថា ភាពងាយស្រួលក្នុងការធ្វើដំណើរនេះ នឹងរួមចំណែកបង្កើនភ្ញៀវទេសចរជប៉ុនមកកម្ពុជា។

ឯកឧត្តម Yukio IMAGAWA ក៏បានសម្ដែងនូវការរីករាយពេញចិត្តចំពោះការកើនឡើងនូវចំនួននិស្សិតកម្ពុជា និងចំនួនអ្នកបច្ចេកទេសកម្ពុជា ដែលទៅទទួលការហ្វឹកហាត់នៅប្រទេសជប៉ុននាពេលបច្ចុប្បន្ននេះ។

ជំនួបរវាង**ឯកឧត្តមទេសរដ្ឋមន្ត្រី** និងឯកឧត្តម Yukio IMAGAWA បានប្រព្រឹត្តទៅក្នុងបរិយាកាសរីករាយ ស្និទ្ធស្នាល ដែលមានលក្ខណៈជាការជួបជុំរវាងមិត្តភក្តិចាស់។

ភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០១៦